# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# កិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ានបូកបី លើកទី៨
# ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ ក្រុងសៀមរាប ព្រះរាជាណាចក្រកម្ពុជា

1. យើង រដ្ឋមន្ត្រីសុខាភិបាលនៃប្រទេសសមាជិកអាស៊ាន តំណាងឱ្យប្រទេសប្រ៊ុយណេដារូសាលឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិប្បតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណៈរដ្ឋហ្វីលីពីន សាធារណរដ្ឋសាំងហ្គាពួរ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម និងរដ្ឋមន្ត្រីសុខាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ជប៉ុន និងសាធារណៈរដ្ឋកូរ៉េ បានដំណើរការកិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ានបូកបី លើកទី៨ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ នៅក្រុងសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា ។
2. យើងបានកត់សម្គាល់ថា កិច្ចសហការក្នុងការអភិវឌ្ឍវិស័យសុខាភិបាល ស្របជាមួយរបៀបវារៈនៃការអភិវឌ្ឍន៍សុខាភិបាលអាស៊ានក្រោយ ឆ្នាំ២០១៥ ដោយផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើសុខភាពល្អជាទូទៅ និងរក្សាភាពសកម្មក្នុងវ័យចំណាស់ បញ្ចប់រាល់ទម្រង់នៃកង្វះអាហារូបត្ថម្ភ ឆ្លើយតបនឹងការគំរាមកំហែងនៃជំងឺឆ្លង និងជំងឺឆ្លងលេចឡើងថ្មី ទប់ស្កាត់ភាពស៊ាំនៃឱសថអង់ទីប៊ីយូទិក ការគ្របដណ្តប់សុខភាពជាសកល ធនធានមនុស្សក្នុងវិស័យសុខាភិបាល វេជ្ជសាស្ត្របុរាណ សុខភាពមាតានិងទារក ការឆ្លើយតបឆាប់រហ័សចំពោះបញ្ហានិងវិបត្តិសុវត្ថិភាពចំណីអាហារ ការតាមដានរកមើល និងផែនការ ដើម្បីធានាសុវត្ថិភាពចំណីអាហារនិងកសាងសមត្ថភាពអង្កេតស្រាវជ្រាវជំងឺរាតត្បាតបង្ករដោយចំណីអាហារ ។
3. យើងប្តេជ្ញាបន្តការខិតខំប្រឹងប្រែង ក្នុងការអនុវត្តន៍ច្បាប់សុខភាពអន្តរជាតិ ( IHR 2005 ) តាមរយៈយុទ្ធសាស្ត្រអាស៊ីប៉ាស៊ីហ្វិក ដើម្បីបង្ការនិងទប់ស្កាត់ជំងឺឆ្លងថ្មីៗ និងគ្រោះអាសន្នសុខភាពសាធារណៈ (APSEDIII) ដើម្បីលើកកំពស់សមត្ថភាពប្រទេសជាសមាជិកអាស៊ាននិងបូកបី ក្នុងការបង្ការស្រាវជ្រាវរក និងឆ្លើយតបទៅនឹងការគំរាមកំហែងសុខភាពសាធារណៈ។ ដើម្បីរក្សាវឌ្ឍនភាពដែលសម្រេចបាន ចាំបាច់ត្រូវ ១) ពង្រឹងការប្រយុទ្ធនឹងភាពស៊ាំឱសថអង់ទីប៊ីយូទិក សុវត្ថិភាពចំណីអាហារ និងគ្រប់គ្រងជំងឺឆ្លងពីសត្វ ២) ពង្រឹងទំនាក់ទំនងអន្តរវិស័យ និងការចែករំលែកព័ត៌មាន ដោយរាប់បញ្ចូលទាំងការចែករំលែកទៀងទាត់របាយការណ៍ អង្កេតស្រាវជ្រាវជំងឺរាតត្បាតរវាងវិស័យសុខាភិបាលនិង វិស័យពាក់ព័ន្ធ ៣) ពង្រឹងយន្តការអន្តរវិស័យដែលមានស្រាប់ ដោយរាប់បញ្ចូលទាំងដៃគូអភិវឌ្ឍន៍ដើម្បីពិនិត្យមើលការអភិវឌ្ឍន៍សមត្ថភាពស្នូលនៃច្បាប់សុខភាពអន្តរជាតិ នៅបណ្តាប្រទេសអាស៊ាននិងបូកបី ។
4. យើងឯកភាពគ្នា ពង្រឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ក្នុងការតស៊ូមតិ សំរបសំរួល និង អនុវត្តអន្តរាគមន៍ក្នុងផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចដែលពាក់ព័ន្ធ ដើម្បីដោះស្រាយជំងឺមិនឆ្លង និងកត្តាហានិភ័យនានា ក្នុងនោះមានជាអាទិ៍ ការប្រើប្រាស់ផលិតផលថ្នាំជក់ គ្រឿងស្រវឹងប្រកបដោយគ្រោះថ្នាក់ របបអាហារប៉ះពាល់សុខភាព និងរបៀបរស់នៅកង្វះកាយវប្បកម្ម ។

5. យើងបញ្ជាក់ថា សុខភាពប្រជាជនយើងមានសារៈសំខាន់ណាស់ ដោយមិនគិតអំពីស្ថានភាពភូមិសាស្ត្រ ភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចឡើយ ។ យើងសូមអះអាងសារជាថ្មី ពីការប្តេជ្ញាចិត្តរបស់យើងចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព របស់អង្គ ការសហប្រជាជាតិ ដើម្បីសម្រេចបានការគ្របដណ្តប់សុខភាពជាសកលនៅឆ្នាំ ២០៣០ រួមមានការបង្ការហានិភ័យហិរញ្ញវត្ថុ លទ្ធភាពទទួលបានសេវាថែទាំសុខភាពជាសារវ័ន្ត ប្រកបដោយគុណភាព និងទទួលបានឱសថសារវ័ន្ត និងវ៉ាក់សាំងមានសុវត្ថិភាព ប្រសិទ្ធភាព គុណភាព ទាំងអស់គ្នា នៅក្នុងតម្លៃសមស្រប ។ ដូច្នេះយើងប្រគល់ភារកិច្ចឱ្យឧត្តមមន្ត្រីសុខាភិបាលអាស៊ានបូកបី ដើម្បីពន្លឿនវឌ្ឍនភាពឆ្ពោះទៅកាន់ការគ្របដណ្តប់សុខភាពជាសកលនៅគ្រប់ប្រទេស ដោយត្រូវកសាងសមត្ថភាពថ្នាក់ជាតិ និងថ្នាក់តំបន់ ក្នុងការវាយតំលៃ និងការគ្រប់គ្រងប្រព័ន្ធសុខាភិបាលប្រកបដោយសមធម៌ និងប្រសិទ្ធភាព ដើម្បីគាំទ្រការគ្របដណ្តប់សុខភាពជាសកល ដោយរួមបញ្ចូលទាំង សកម្មភាពដែលស្ថិតនៅក្រោមបណ្តាញការគ្របដណ្តប់សុខភាពជាសកលនៃអាស៊ានបូកបី ។
6. យើងទទួលស្គាល់ សកម្មភាពសុខភាពជាសក្តានុពល ដែលត្រូវអនុវត្ត នៅក្នុងក្របខ័ណ្ឌអាស៊ានបូកបី ដូច្នេះយើងជំរុញឱ្យឧត្តមមន្ត្រីអាស៊ានបូកបី ពិចារណាអំពីគំនិតផ្តួចផ្តើមនានា ដែលត្រូវបានកំណត់ថាជាលក្ខណៈតំបន់ ហើយគំនិតផ្តួចផ្តើមទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីការងារថ្មី ក្នុងចង្កោមសុខាភិបាលអាស៊ាន ។
7. យើងកត់សំគាល់ពីការរួមចំណែករបស់ដៃគូអភិវឌ្ឍន៍ និងដៃគូសន្ទនា ដូច្នេះយើង ប្តេជ្ញាចិត្តបន្តសហការយ៉ាងជិតស្និទ្ធជាមួយដៃគូទាំងនោះ ដោយប្រកាន់ភ្ជាប់នូវ «វិធាននិងនិតិវិធីស្តីពីការចូលរួមរបស់អង្គភាពនានា ក្នុងវិស័យសុខាភិបាលអាស៊ាន» ។

យើងនឹងបន្តការផ្លាស់ប្តូរទស្សនៈ និងកិច្ចសហការក្នុងការអភិវឌ្ឍវិស័យសុខាភិបាល នៅឯកិច្ចប្រជុំបន្ទាប់នៅសាធារណៈរដ្ឋឥណ្ឌូនេស៊ី ក្នុងឆ្នាំ ២០២១ ។

********

FINAL

**JOINT STATEMENT**
**8TH ASEAN PLUS THREE HEALTH MINISTERS MEETING**
**30 AUGUST 2019, SIEM REAP, THE KINGDOM OF CAMBODIA**

1. WE, the Ministers of Health of ASEAN Member States (AMS), representing Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Viet Nam and the Ministers of Health of the People's Republic of China, Japan and the Republic of Korea convened the 8th ASEAN Plus Three Health Ministers Meeting (APTHMM) on 30 August 2019 in Siem Reap, the Kingdom of Cambodia.

2. We note that our health development collaboration are aligned with the ASEAN Post-2015 Health Development Agenda with specific focus on common concerns on healthy and active ageing, ending all forms of malnutrition, responding to communicable and emerging health threats, antimicrobial resistance, universal health coverage, human resources for health, traditional and complementary medicine, maternal and child health, rapid response in food safety issues and crisis, traceability and recall plan in ensuring food safety, and food-borne outbreak investigation capacity building.

3. We commit to continue our efforts on the implementation of IHR, Asia Pacific Strategy for Emerging Diseases and Public Health Emergencies (APSED III) to enhance AMS and Plus Three countries' capacity to prevent, detect, and respond to public health threats. In sustaining the progress made, there is further need to strengthen: (1) combating antimicrobial resistance, food safety and zoonotic disease control, (2) inter-sectoral communications and information-sharing including the regular sharing of outbreak investigation reports between human and other relevant sectors, and (3) existing inter-sectoral mechanism, which includes Development Partners, to oversee IHR core capacity development within AMS and Plus Three countries.

4. We agree to strengthen our joint efforts in advocating, facilitating and implementing relevant social and economic interventions in addressing non-communicable diseases and its risk factors including tobacco consumption and the harmful use of alcohol and unhealthy diet, as well as inactive lifestyle.

5. We affirm that the health of our populations to be of paramount importance irrespective of our geographical, geopolitical and economic status. We reaffirm our commitments to the United Nations SDGs to achieve Universal Health Coverage (UHC) by 2030 which includes financial risk protection, access to quality essential health-care services and access to safe, effective, quality and affordable essential medicines and vaccines for all. We therefore task the ASEAN Plus Three SOMHD

to accelerate the progress towards UHC in all countries by building up the national and regional capacity to assess and manage the equitable and efficient health systems to support UHC, including activities under the ASEAN Plus Three UHC Network.

6. We acknowledge the potential health activities to be undertaken under the ASEAN Plus Three and therefore urge ASEAN Plus Three SOMHD to consider initiatives that are identified as regional in nature, to be incorporated in the new Work Programmes of relevant ASEAN Health Clusters.

7. We note the contribution by, and further commit to collaborate closely with Dialogue and Development Partners, with adherence to the *Rules of Procedure on the Engagement of Entities with the ASEAN Health Sector*.

We look forward to further exchanges of views and collaboration in health development at our next Meeting in the Republic of Indonesia in 2021.

********